**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១៣៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការរៀបចំបង្កើតឯកសណ្ឋាន និង សញ្ញាសម្គាល់ សំរាប់មន្ត្រីរាជការនៃក្រសួងពាណិជ្ជកម្ម

*************

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ ២០អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន

-បានឃើញអនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សំរេច

**មាត្រា១.** អនុញ្ញាតឱ្យក្រសួងពាណិជ្ជកម្មបង្កើតឯកសណ្ឋាន (រួមមានទាំងសញ្ញាសម្គាល់របស់ក្រសួងពាណិជ្ជកម្មនិងស្លាកសម្គាល់ឈ្មោះមន្ត្រីរាជការបំពាក់លើឯកសណ្ឋាន) សំរាប់មន្ត្រីរាជការនៃក្រសួងពាណិជ្ជកម្មប្រើប្រាស់ក្នុងពេលប្រតិបត្តិការងារ លើកលែងតែមន្ត្រីរាជការនៃនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ "កាំកុងត្រូល" មានឯកសណ្ឋានដោយឡែក ។

**មាត្រា២.** ឯកសណ្ឋានសំរាប់សម្គាល់មន្ត្រីរាជការរបស់ក្រសួងពាណិជ្ជកម្មត្រូវបានកំណត់ជាបីថ្នាក់ដូចតទៅ :

**ក-ឯកសណ្ឋានមន្ត្រីពាណិជ្ជកម្មចាប់ពី អនុប្រធាននាយកដ្ឋានឡើង**

**-សំរាប់បុរស :**

. **ខោជើងវែង :** ពណ៌សណ្តែកខ្ចី ផលិតពីក្រណាត់តេហ្គាលឡែន ចង្កេះត ថ្នេរបង្កប់ជីបភ្លីខាងមុខ មានហោប៉ៅបី "ហោប៉ៅខាងក្រោយមួយដេរបង្កប់ មានគំរបរាងស្លឹកពោធិ និងហោប៉ៅពីរទៀតនៅចំហៀង ដេរបង្កប់តាមថ្នេរ" ។

. **អាវ :** អាវដៃខ្លី កបើកថ្នេរឌុបមានពណ៌និងសាច់ក្រណាត់ដូចខោ មានហោប៉ៅបួន ដេរប៉ះមានគំរបរាងស្លឹកពោធិ មានឡេវពណ៌មាសរូបព្រះសង្ខ ។

**-សំរាប់នារី :**

.**ខោជើងវែង :** ពណ៌សណ្តែកខ្ចី ផលិតពីក្រណាត់តេហ្គាលឡែន ចង្កេះត ថ្នេរបង្កប់ជីបភ្លីខាងមុខ មានហោប៉ៅបី "ហោប៉ៅខាងក្រោយមួយដេរបង្កប់មានគំរបរាងស្លឹកពោធិ និងហោប៉ៅពីរទៀតនៅចំហៀង ដេរបង្កប់តាមថ្នេរ" ។

. **អាវ :** អាវដៃខ្លី កឌុប ថ្នេរឌុបមានពណ៌និងសាច់ក្រណាត់ដូចខោ មានហោប៉ៅបួន ដេរប៉ះ មានគំរបរាងស្លឹកពោធិ មានឡេវពណ៌មាសរូបព្រះសង្ខ ។

**ខ-ឯកសណ្ឋានមន្ត្រីពាណិជ្ជកម្មថ្នាក់ការិយាល័យ**

**-សំរាប់បុរស :**

.**ខោជើងវែង :** ពណ៌សណ្តែកខ្ចី ផលិតពីក្រណាត់តេហ្គាលឡែន ចង្កេះត ថ្នេរបង្កប់ជីបភ្លីខ មានហោប៉ៅបី "ហោប៉ៅខាងក្រោយមួយដេរបង្កប់ មានគំរបរាងស្លឹកពោធិ និងហោប៉ៅពីរទៀតនៅ ចំហៀង ដេរបង្កប់តាមថ្នេរ" ។

. **អាវ :** អាវដៃខ្លី កបើកថ្នេរឌុបមានពណ៌និងសាច់ក្រណាត់ដូចខោ មានហោប៉ៅបួន ដេរប៉ះ មានគំរបរាងស្លឹកពោធិ ។

**- សំរាប់នារី :**

. **ខោជើងវែង :** ពណ៌សណ្តែកខ្ចី ផលិតពីក្រណាត់តេហ្គាលឡែន ចង្កេះត ថ្នេរបង្កប់ជីបភ្លីខាងមុខ មានហោប៉ៅបី "ហោប៉ៅខាងក្រោយមួយដេរបង្កប់ មានគំរបរាងស្លឹកពោធិ និងហោប៉ៅពីរទៀតនៅចំហៀង ដេរបង្កប់តាមថ្នេរ" ។

. **អាវ :** អាវដៃខ្លី កឌុបថ្នេរឌុប មានជីបចង្កេះ ពណ៌និងសាច់ក្រណាត់ដូចខោ មានហោប៉ៅបួន ដេរប៉ះ មានគំរបរាងស្លឹកពោធិ ។

**ឥ-ឯកសណ្ឋានមន្ត្រីពាណិជ្ជកម្ម**

- **សំរាប់បុរស :**

. **ខោជើងវែង :** ពណ៌សំណ្តែកខ្ចី ផលិតពីក្រណាត់តេហ្កាលឡែន ចង្កេះត ថ្នេរបង្កប់ជីបភ្លីខាងមុខ មានហោប៉ៅបី "ហោប៉ៅខាងក្រោយមួយដេរបង្កប់ មានគំរបរាងស្លឹកពោធិ និងហោប៉ៅពីរទៀតនៅចំហៀង ដេរបង្កប់តាមថ្នេរ" ។

. **អាវ :** អាវដៃវែងកបើកថ្នេរឌុបមានពណ៌និងសាច់ក្រណាត់ដូចខោមានហោប៉ៅពីរដេរប៉ះ បត់ផ្នត់កណ្តាល មានគំរបរាងស្លឹកពោធិ កាត់ស្រុងវែងជើងត្រង់ ។

- **សំរាប់នារី :**

. **ខោជើងវែង :** ពណ៌សំណ្តែកខ្ចី ផលិតពីក្រណាត់តេហ្កាលឡែន ចង្កេះត ថ្នេរបង្កប់ជីបភ្លីខាងមុខ មានហោប៉ៅបី "ហោប៉ៅខាងក្រោយមួយដេរបង្កប់ មានគំរបរាងស្លឹកពោធិ និងហោប៉ៅពីរទៀតនៅចំហៀង ដេរបង្កប់តាមថ្នេរ" ។

. **អាវ :** អាវដៃខ្លីកឌុបថ្នេរឌុប មានជីបចង្កេះ ពណ៌និងសាច់ក្រណាត់ដូចខោមានហោប៉ៅពីរ ដេរប៉ះ មានគំរបរាងស្លឹកពោធិ កាត់ស្រុងវែងជើងត្រង់ ។

**ឃ-ស្លាកសម្គាល់ឈ្មោះមន្ត្រី :**

ស្លាកសម្គាល់ឈ្មោះមន្ត្រីរាជការ មានរាងបួនជ្រុងទ្រវែង បណ្តោយ ១០សង់ទីម៉ែត្រ ទទឹង០២សង់ទីម៉ែត្រ ធ្វើពីជាតិជ័ររឹង មានរូបសញ្ញាសម្គាល់ក្រសួងពាណិជ្ជកម្ម នៅចំហៀងខាងស្តាំ និងចំហៀងខាងឆ្វេង មានសរសេរឈ្មោះមន្ត្រី ជាអក្សរខ្មែរនៅជួរលើ និងអត្តលេខជាលេខសកលនៅជួរក្រោម ។ ស្លាកសម្គាល់នេះសម្រាប់រំពាក់លើគម្របហោប៉ៅខាងស្តាំ ចែកជាបីថ្នាក់ :

- **ថ្នាក់អនុប្រធាននាយកដ្ឋានឡើង :** បន្ទះជ័រជាស្លាកសម្គាល់ឈ្មោះមន្ត្រី មានផ្ទៃពណ៌ទឹកប៊ិច ព័ទ្ធជុំវិញដោយខ្សែបន្ទាត់ពណ៌មាសបិទជិត ។ អក្សរ និងអត្តលេខសរសេរពណ៌មាស ។
- **ថ្នាក់ការិយាល័យ :** បន្ទះជ័រជាស្លាកសម្គាល់ឈ្មោះមន្ត្រី មានផ្ទៃពណ៌ទឹកប៊ិច ព័ទ្ធជុំវិញដោយខ្សែបន្ទាត់ពណ៌ប្រាក់បិទជិត ។ អក្សរ និងអត្តលេខសរសេរពណ៌ប្រាក់ ។
- **ថ្នាក់មន្ត្រី :** បន្ទះជ័រជាស្លាកសម្គាល់ឈ្មោះមន្ត្រី មានផ្ទៃពណ៌ទឹកសមុទ្រ ។ អក្សរនិងអត្តលេខសរសេរពណ៌ស ។

**មាត្រា៣.** ឯកសណ្ឋានដូចមានចែងក្នុងមាត្រា២ ខាងលើនេះ ត្រូវភ្ជាប់នូវរូបសញ្ញាសម្គាល់របស់ក្រសួងពាណិជ្ជកម្ម នៅលើដើមដៃអាវខាងស្តាំ សំរាប់មន្ត្រីរាជការស្លៀកពាក់ ក្នុងពេលចុះបំពេញបេសកកម្មការងារ ឬក្នុងពិធីផ្លូវការផ្សេងៗរបស់ក្រសួងពាណិជ្ជកម្ម ។

**មាត្រា៤.-** ឯកសណ្ឋានសំរាប់មន្ត្រីរាជការ ផ្តល់ជូនចំនួន ០២សំរាប់ (ពីរសំរាប់) ក្នុងរយៈពេលមួយឆ្នាំ ។

**មាត្រា៥.-** ជនណាក្លែងបន្លំខ្លួនស្លៀកពាក់ឯកសណ្ឋាន ដោយមានភ្ជាប់ស្លាកសម្គាល់ឈ្មោះ និងសញ្ញាសម្គាល់របស់ក្រសួងពាណិជ្ជកម្ម ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**មាត្រា៦.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័ន និង គ្រប់ខេត្ត ក្រុង ពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ [illegible] ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>កន្លែងទទួល</u> :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា៦

- រាជកិច្ច

-ឯកសារ - កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

## នៃអនុក្រឹត្យលេខ១៣៨ អនក្រ.បក ចុះថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ ២០០៦

## ស្តីពីការបង្កើតឯកសណ្ឋាន និងសញ្ញាសម្គាល់មន្ត្រីរាជការ

## ក្រសួងពាណិជ្ជកម្ម

### ឯកសណ្ឋានសម្រាប់ថ្នាក់នាយកដ្ឋាន

បុរស នារី



**ឧបសម្ព័ន្ធទី២**

**នៃអនុក្រឹត្យលេខ១៣៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៦**

**ស្តីពីការបង្កើតឯកសណ្ឋាន និងសញ្ញាសម្គាល់មន្ត្រីរាជការ**

**ក្រសួងពាណិជ្ជកម្ម**

**ឯកសណ្ឋានសម្រាប់ថ្នាក់ការិយាល័យ**

**បុរស** **នារី**



# ឧបសម្ព័ន្ធទី៣

## នៃអនុក្រឹត្យលេខ១៣៧ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ ២០០៦

## ស្តីពីការបង្កើតឯកសណ្ឋាន និងសញ្ញាសម្គាល់មន្ត្រីរាជការ

## ក្រសួងពាណិជ្ជកម្ម

## ឯកសណ្ឋានសម្រាប់មន្ត្រី

បុរស



នារី



## ឧបសម្ព័ន្ធទី៤

## នៃអនុក្រឹត្យលេខ១៣៧ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៦

## ស្តីពីការបង្កើតឯកសណ្ឋាន និងសញ្ញាសម្គាល់មន្ត្រីរាជការ

## ក្រសួងពាណិជ្ជកម្ម

## សញ្ញាសម្គាល់ឈ្មោះមន្ត្រីរាជការ

ក. ថ្នាក់នាយកដ្ឋាន




ខ. ថ្នាក់ការិយាល័យ




គ. មន្ត្រី



# ឧបសម្ព័ន្ធទី៥

## នៃអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ ២០០៦

## ស្តីពីការបង្កើតឯកសណ្ឋាន និងសញ្ញាសម្គាល់មន្ត្រីរាជការ

## ក្រសួងពាណិជ្ជកម្ម

## ផ្លាកសំគាល់សញ្ញាក្រសួងពាណិជ្ជកម្ម